៣-ឯកឧត្តម **ត្រាក់ ថៃសៀង** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរងទី១ រាជធានីភ្នំពេញ ជាសមាជិក

៤-លោក **អ៊ីង ជុនឃួរ** អគ្គនាយករងក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៥-លោក **ឃាន់ វិបុលចន្ទ្រា** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខក្រសួងមហាផ្ទៃ ជាសមាជិក

៦-លោក **ឡោ ជាវុធ** ប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

**មាត្រា ២.-** ក្រុមការងារនេះដំណើរការ ការងារក្រោមការដឹកនាំរបស់ប្រធាន រឺ សមាជិកណាម្នាក់ដែលប្រធានប្រគល់សិទ្ធិឱ្យ ។

**មាត្រា ៣.-** ក្នុងករណីចាំបាច់ ប្រធានក្រុមការងារបច្ចេកទេសជាន់ខ្ពស់ អាចលើកសំណើបំពេញបន្ថែមសមាជិករបស់ខ្លួនតាមតំរូវការជាក់ស្តែង ។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមអគ្គលេខាធិការ អាជ្ញាធរជាតិទទួលបន្ទុកការងារអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមណ៍ ពត៌មានវិទ្យា ឯកឧត្តម អស់លោកតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ៤៦ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា

តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១.-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣.៧០៥លានរៀល (បីពាន់ប្រាំពីររយប្រាំលានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមក

ជំពូក ១០ (បៀវត្ស និងប្រាក់បំណាច់) ចំនួន ៥២៥លានរៀល . ជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ចំនួន ៣.០០០លានរៀល និង មកជំពូក ៣១ (អន្តរាគមណ៍ក្នុង វិស័យ សង្គមកិច្ច និង វប្បធម៌) ចំនួន ១៨០លានរៀល របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់ គ្រងឆ្នាំ ២០០១។

**មាត្រា ២.-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយលើប្រាក់ម៉ោងសាស្ត្រាចារ្យ. ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី និង អាហារូបករណ៍និស្សិត វគ្គបណ្តុះបណ្តាលបរិញ្ញាប័ត្រជាន់ខ្ពស់ ជំនាន់ទី ១ នៅរាជបណ្ឌិតសភាកម្ពុជា។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

* * *

**អនុក្រឹត្យលេខ ២២៩ អនក្រ.បក**

**ស្តីពី**

**ការជួនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី